# របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
# ក្រោមប្រធានបទ សំណើសុំក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយរដ្ឋធម្មនុញ្ញ
# បកស្រាយរដ្ឋធម្មនុញ្ញរាជាណាចក្រកម្ពុជាត្រង់ជំពូកទី២
# ត្រង់វគ្គស្តីអំពីតួនាទីរបស់ព្រះមហាក្សត្រខ្មែរ ។

Website: www.hoksavann.org

ថ្ងៃទី១១ មេសា ២០១០



សំណើនេះកើតឡើងដោយយើងបានទទួលដំណឹងថា ព្រះករុណាសម្តេចព្រះនរោត្តម-សីហនុ អតីតព្រះមហាក្សត្រខ្មែរនឹងយាងទៅធ្វើទស្សនកិច្ចនៅប្រទេសវៀតណាមនៅខែមិថុនា ។ ដំណឹងនេះបានធ្វើឲ្យតំណាងរាស្ត្រពីររូបនឹងធ្វើសំណើទៅអតីតព្រះមហាក្សត្រខ្មែរ គឺតំណាងរាស្ត្រម្នាក់នឹងធ្វើសំណើទៅអតីតព្រះមហាក្សត្រខ្មែរ សូមលើកយកបញ្ហាព្រំដែនខ្មែរ-វៀតណាមពិភាក្សាជាមួយវៀតណាម ។ ឯតំណាងរាស្ត្រម្នាក់ទៀត សូមលើកយកបញ្ហាខ្មែរកម្ពុជាក្រោមទៅពិភាក្សាជាមួយវៀតណាម ។ បន្ទាប់ពីបានទទួលដំណឹងអំពីគោលបំណងរបស់តំណាងរាស្ត្រទាំងពីររូបនោះមក ព្រះអង្គម្ចាស់ស៊ីសុវត្ថិ-ធម្មិកោ ទីប្រឹក្សាអមខុទ្ទកាល័យព្រះមហាក្សត្របានពោលថា បើយោងតាមរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្រក្តី ព្រះអតីតព្រះមហាក្សត្រក្តី ពុំមានរាជសិទ្ធិណាមួយក្នុងការជជែកវែកញែកពិភាក្សាអំពីបញ្ហានយោបាយឡើយ ។

ក្នុងវគ្គស្តីអំពីតួនាទីរបស់ព្រះមហាក្សត្រខ្មែរមានរហូតដល់២៤មាត្រា គឺចាប់ពីមាត្រាទី៧រហូតដល់មាត្រាទី៣០ ។ ក្នុងមាត្រាទាំងនោះ មានមាត្រាខ្លះងាយយល់ មាត្រាខ្លះត្រូវតែបកស្រាយបន្ថែមទើបយល់បាន ។ ក្នុងពេលនេះយើងលើកយកមាត្រាបី ដែលគួរតែក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយ គឺមាត្រា៨ មាត្រា២៣ និងមាត្រា២៧ ។

ត្រង់មាត្រា៨ចែងថា ៖ «ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាគោរពសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសិទ្ធិសញ្ញាអន្តរជាតិ» ។ មាត្រាទី៨នេះស្របតាមសំណើរបស់តំណាងរាស្ត្រទាំងពីររូប ចំពោះតួនាទីរបស់ព្រះមហាក្សត្រ ។ តើពាក្យថាធានានេះមានន័យដូចម្តេច? បើធានាគ្មានធ្វើសកម្មភាពអ្វីសោះ តើអាចការពារឯករាជ្យ ការពារទឹកដីបានឬទេ ? បើមុខងារព្រះមហាក្សត្រមានត្រឹមតែប្រថាប់ត្រាទេ ពាក្យថាធានាមិនចាំបាច់ត្រូវដាក់ទេ ព្រោះថាបើស្ថាប័នទាំងបី រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលធ្វើខុស ព្រះមហាក្សត្រគ្មានសិទ្ធិជំទាស់បានទេ ត្រូវតែប្រថាប់ត្រាជាដាច់ខាត ។ ពាក្យថាធានាមានន័យថា ការពារកុំឲ្យបាត់បង់ ត្រូវមានសិទ្ធិជជែកវែកញែកពិភាក្សានិងមានសិទ្ធិសំរេច ។ ត្រង់នេះត្រូវស្ថិតនៅលើក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានកាតព្វកិច្ចត្រូវបកស្រាយការពិតឲ្យបានច្បាស់លាស់ ។

មាត្រា២៣បានចែងថា ៖ «ព្រះមហាក្សត្រត្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ ។ អគ្គមេបញ្ជាការកងខេមរភូមិន្ទ ត្រូវបានតែងតាំងឡើង ដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ» ។ ត្រង់មាត្រានេះហាក់ដូចជានៅលើក្រដាសនៅឡើយ មិនទាន់ឃើញសកម្មភាពណាមួយដែលបញ្ជាក់ថា ព្រះអង្គមានសិទ្ធិកំពូលនៃការបញ្ជាកងទ័ព ។ អំណាចបញ្ជាកងទ័ពឃើញតែស្ថាប័ននីតិប្រតិបត្តិគឺរាជរដ្ឋាភិបាល ហើយមិនឮថាទៅទាក់ទងនឹងមហាក្សត្រឡើយ ។ ត្រង់នេះមានតែក្រុមប្រឹក្សាធម្មនុញ្ញគប្បីបកស្រាយនូវមាត្រា២៣នេះឲ្យបានច្បាស់លាស់ ។

មាត្រា២៧ ៖ «ព្រះមហាក្សត្រទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស» ។ ត្រង់មាត្រានេះ មិនឃើញព្រះអង្គបន្ធូរបន្ថយទោស និងលើកលែងទោសដោយយោបល់ព្រះអង្គផ្ទាល់ឡើយ ។ ព្រះអង្គលើកលែងទោសដោយសារសំណើរបស់មន្ត្រីក្រសួងយុត្តិធម៌ និងពីនាយករដ្ឋមន្ត្រីប៉ុណ្ណោះ ។ ត្រង់មាត្រា២៧នេះ មិនឃើញបញ្ជាក់ថា ព្រះអង្គអាចបន្ធូរបន្ថយទោសឬលើកលែងទោសចំពោះអ្នកទោសណាបាន លុះត្រាតែមានសំណើឬយល់ព្រមពីនាយករដ្ឋមន្ត្រីផងឡើយ ។ ការលើកលែងទោសកន្លងមកហើយ ឃើញតែនាយករដ្ឋមន្ត្រីស្នើទៅព្រះមហាក្សត្រ ទើបព្រះអង្គលើកលែងទោសទៅតាមសំណើនោះ ។ តាមន័យប្រាកដបែបណា មានតែក្រុមប្រឹក្សាធម្មនុញ្ញគប្បីបកស្រាយឲ្យបានច្បាស់លាស់ ។

អត្ថបទរបស់ព្រះករុណាសម្តេចនរោត្ត-សីហនុដែលសរសេរទាក់ទងនឹងព្រំដែនខ្មែរ-វៀតណាម នៅថ្ងៃ២៩ ឧសភា ២០០៥ «ព្រះអង្គមិនទទួលស្គាល់ថាមានតំបន់សឡើយ ។ តាំងពីឆ្នាំ១៩៧៩ ទឹកទន្លេរបស់កម្ពុជាមួយភាគបានប្រគល់ឲ្យវៀតណាម ។ ការបង្ខិតក្លោងទ្វារនិងថ្មកំណត់ព្រំដែននៃប្រទេសជិតខាងចូលមកដីកម្ពុជាយ៉ាងជ្រៅរហូតដល់ទៅ១៧គ.ម. ឬក៏លើសពីនេះទៅទៀត» ។ល។ ដូច្នេះព្រះករុណាសម្តេចនរោត្តម-សីហនុព្រះអង្គប្រឆាំងនឹងការឈ្លានពានទឹកដីកម្ពុជាពីសំ-ណាក់វៀតណាម ដូចអ្នកស្នេហាជាតិដទៃទៀតដែរ ។ តើព្រះអង្គអាចបំភ្លេចនូវឧត្តមគតិស្នេហាជាតិនេះចោលដោយមូលហេតុអ្វីមួយ ? នៅខែមិថុនាដែលព្រះអង្គនឹងយាងទៅធ្វើទស្សនកិច្ចប្រទេសវៀតណាម តើព្រះអង្គអាចលើកយកបញ្ហាព្រំដែននេះមកចរចាជាមួយវៀតណាម បើមិនក្នុងនាមជាអតីតព្រះមហាក្សត្រទេ ក៏ក្នុងនាមជាពលរដ្ឋខ្មែរមួយព្រះអង្គដែរ ។ ចរចាអំពីភាពពិតដែលព្រះអង្គបានជ្រាបជាហូរហែមកអំពីបញ្ហាទឹកដីនេះ ។ វៀតណាមនឹងយកចិត្តទុកដាក់ដោយសារព្រះអង្គធ្លាប់មានគុណលើប្រទេសវៀតណាម ។ ចំពោះបញ្ហាខ្មែរកម្ពុជាក្រោមវិញ ព្រះអង្គគ្រាន់តែសុំសំណូមពរទៅវៀតណាម កុំឲ្យធ្វើទុក្ខបុកម្នេញបងប្អូនខ្មែរកម្ពុជាក្រោម ។ បើធ្វើសំណូមពរប៉ុណ្ណោះទាក់ទងនឹងច្បាប់អន្តរជាតិជាសំណូមពរបែបមនុស្សធម៌មិនទាក់ទងនយោបាយឡើយ ។ ឯបញ្ហាទាមទារកម្ពុជាក្រោមជាស្វយ័តឬឯករាជ្យ ជាភារកិច្ចរបស់បងប្អូនខ្មែរកម្ពុជាក្រោមដោយផ្ទាល់ខ្លួន ។ តើព្រះអង្គអាចធ្វើតាមសំណើរបស់តំណាងរាស្ត្រទាំងពីររូបបែបនេះបានឬទេ ? ។